**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករគណនេយ្យនិងសវនកម្ម**
លេខ ០០២១ ន.គ.ស.សរ.ន.៣

ថ្ងៃព្រហស្បតិ៍ ៧កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១

# សេចក្តីជូនដំណឹងសារជាថ្មី
## ស្តីពី
## ការជ្រើសរើសក្រុមហ៊ុន ឬវិទ្យាស្ថានវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម លើការបណ្តុះបណ្តាលស្តង់ដាគណនេយ្យសម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ

**និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស)** គឺជាស្ថាប័ននិយ័តករគណនេយ្យនិងសវនកម្មតែមួយគត់នៅកម្ពុជាដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មប្រកបដោយការជឿទុកចិត្តពីស្ថាប័នសាធារណៈ ស្ថាប័នឯកជន គណនេយ្យករ សវនករ និងសាធារណជន។ ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន **ន.គ.ស** បានដាក់ចេញនូវផែនការបណ្តុះបណ្តាលស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនធំ សហគ្រាសធុនតូច និងមធ្យម អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដើម្បីបញ្ជ្រាបការយល់ដឹងលើស្តង់ដាគណនេយ្យឱ្យបានទូលំទូលាយ ទាំងការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មស្របតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានដែលនឹងត្រូវធ្វើឡើងដោយក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលមានជំនាញវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ដែលមានគុណវុឌ្ឍិខ្ពស់លើវិស័យគណនេយ្យ និងសវនកម្ម។

ក្នុងន័យនេះ **ន.គ.ស** សូមប្រកាសជ្រើសរើសក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលមានគុណវុឌ្ឍិដូចខាងក្រោម÷

**១. លក្ខខណ្ឌគុណវុឌ្ឍិ**

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែជាក្រុមហ៊ុនដែល÷

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងនៅអគ្គនាយកដ្ឋានពន្ធដារ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បានអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មពេញលេញ
- មានចំណេះដឹងអំពីស្តង់ដាគណនេយ្យ និងសវនកម្មដែលបានដាក់ឱ្យអនុវត្តជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- មានបទពិសោធន៍បណ្តុះបណ្តាលក្នុងវិស័យគណនេយ្យ និងសវនកម្មរយៈពេលយ៉ាងតិច១០ឆ្នាំ
- ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត។

**២. សមិទ្ធផលដែលត្រូវផ្តល់**

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលទទួលជោគជ័យក្នុងការដេញថ្លៃ ត្រូវផ្តល់ជូន **ន.គ.ស** នូវការបណ្តុះបណ្តាលស្តង់ដាគណនេយ្យសម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដល់សិក្ខាកាមដែលកំណត់ដោយ **ន.គ.ស** បានគ្រប់ចំនួន និងទាន់ពេលវេលាប្រកដោយប្រសិទ្ធភាពខ្ពស់ ដោយភ្ជាប់បង្ហាញជាមួយនូវរបាយការណ៍ការបណ្តុះបណ្តាល។

**៣. តម្លៃ**

កម្រៃសម្រាប់ការបណ្តុះបណ្តាល គឺបើកចំហរសម្រាប់ការចរចារ។

**៤. រយៈពេលសម្រាប់ការបណ្តុះបណ្តាល**

ការបណ្តុះបណ្តាលស្តង់ដាគណនេយ្យខាងលើនេះមានរយៈពេលមិនលើស២ (ពីរ) ខែ។ ក្នុងករណីមានការបន្ត ឬពន្យារពេលក្នុងបណ្តុះបណ្តាលលើស ២ (ពីរ) ខែ នឹងត្រូវមានការពិភាក្សា និងចរចារ។

កិច្ចសន្យានៃការផ្តល់សេវាបណ្តុះបណ្តាល នឹងត្រូវបង្កើតឡើងរវាង**ន.គ.ស** ជាមួយនឹងក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលបានទទួលជោគជ័យក្នុងការដេញថ្លៃ។

**៥. ការដាក់ពាក្យ**

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលមានចំណាប់អារម្មណ៍ សូមផ្ញើសេចក្តីចំណាប់អារម្មណ៍មក **ន.គ.ស** តាមរយៈអ៊ីម៉ែល b.tharin@acar.gov.kh និង n.bony@acar.gov.kh ត្រឹមថ្ងៃទី ខែ ឆ្នាំ២០២១។ ចំពោះក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលបានជាប់ក្នុងបញ្ជីសម្រាំងនឹងត្រូវបានជូនដំណឹងដើម្បីដាក់សំណើបច្ចេកទេស (Technical Proposal) និងសំណើហិរញ្ញវត្ថុ (Financial Proposal)។

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទាក់ទងតាមអាសយដ្ឋាន ឬលេខទូរស័ព្ទ ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគារ "ក" ជាន់ទី១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទទាក់ទង ÷ ០១២ ៧៩៣ ៣៩៨
- Telegram ÷ ០១២ ៧៩៣ ៣៩៨

**និយ័តករគណនេយ្យនិងសវនកម្ម**